# បទប្បញ្ញត្តិទូទៅសម្រាប់បេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ វិន័យក្នុងការប្រឡងឱ្យបានល្អបេក្ខជនទាំងឡាយ ត្រូវគោរព បទប្បញ្ញត្តិនៃការប្រឡងដូចមានចែងខាងក្រោមៈ

## I. ប្រការដែលបេក្ខជនត្រូវអនុវត្ត

១-ត្រូវមកដល់មណ្ឌលប្រឡងឱ្យបានមុនដំណើរការនៃការប្រឡង

២-ត្រូវស្លៀកពាក់ឯកសណ្ឋានសិស្ស ដោយប្រើអាវពណ៌ស និងខោឬសំពត់ពណ៌ខៀវ ដាក់ក្នុងខោ ឬក្នុងសំពត់ ឱ្យបានត្រឹមត្រូវ

៣-ត្រូវយកមកនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតសម្គាល់ខ្លួនមានបិទរូបថតថ្មី និងមានចុះហត្ថលេខា នាយកសាលាត្រឹមត្រូវច្បាស់លាស់។ ចំពោះបេក្ខជនសេរីត្រូវយកមកនូវសលាកបត្រឯកត្តជន ដែលមានចុះហត្ថលេខារបស់មន្ទីរអប់រំយុវជន និងកីឡារាជធានី ខេត្ត

៤-ត្រូវយកចូលក្នុងបន្ទប់ប្រឡងនូវសម្ភារៈប្រើប្រាស់ ដែលក្រសួងអប់រំ យុវជន និងកីឡាអនុញ្ញាតឱ្យ ប្រើៈ ប៊ិចពណ៌ខៀវ ខ្មៅដៃ បន្ទាត់ ដែកឈាន រ៉ាបត័រទ័រ។ ចំពោះខ្មៅដៃពណ៌ ឬហ្វឺតពណ៌ អនុញ្ញាតឱ្យប្រើតែវិញ្ញាសាជីវវិទ្យា ភូមិវិទ្យា និងផែនដី និងបរិស្ថានវិទ្យាប៉ុណ្ណោះ

៥-ត្រូវអនុវត្តតាមការណែនាំរបស់គណៈមេប្រយោគ និងអ្នកមានសមត្ថកិច្ចថែរក្សាសណ្តាប់ធ្នាប់ក្នុងការ ដកហូតសំណៅឯកសារ និងសម្ភារៈផ្សេងៗ ដែលក្រសួងមិនអនុញ្ញាតឱ្យយកចូលក្នុងមណ្ឌល ប្រឡង ឬបន្ទប់ប្រឡង

៦-ត្រូវគោរពតាមការណែនាំរបស់អនុរក្សដូចជា អង្គុយឱ្យចំតាមលេខតុ ដែលអនុរក្សបានបង្ហាញ បំពេញលើក្បាលសន្លឹកកិច្ចការ ដែលអនុរក្សបានចែកឱ្យ ប្រគល់សន្លឹកកិច្ចការជូនអនុរក្សវិញនៅ ពេលដល់ម៉ោង ទោះបីកិច្ចការនោះបានធ្វើ ឬពុំបានធ្វើក៏ដោយ

៧-ត្រូវរក្សាសណ្តាប់ធ្នាប់របៀបរៀបរយនៃការប្រឡង និងត្រូវគោរពឱ្យបានត្រឹមត្រូវនូវបទប្បញ្ញត្តិនៃការ ប្រឡង។

## II. ប្រការដែលបេក្ខជនមិនត្រូវអនុវត្ត

១-មិនត្រូវមកដល់មណ្ឌលប្រឡងក្រោយជួងទី២

២-មិនត្រូវស្លៀកពាក់ឯកសណ្ឋានកងប្រដាប់អាវុធចូលក្នុងមណ្ឌលប្រឡង

៣-មិនត្រូវយកសៀវភៅ និងសំណៅឯកសារគ្រប់រូបភាពចូលក្នុងមណ្ឌលប្រឡង

៤-មិនត្រូវយកចូលក្នុងមណ្ឌលប្រឡង ឬបន្ទប់ប្រឡងនូវ អាវុធ ជាតិផ្ទុះ ទូរស័ព្ទដៃ ឧបករណ៍ អេឡិចត្រូនិចគ្រប់ប្រភេទ សៀវភៅ សំណៅឯកសារ ប្រដាប់គិតលេខ នាឡិកាដៃ ដែលមាន ប្រដាប់គិតលេខ កាតាប កាបូបយួរដៃ ថង់ សំពៀត កញ្ចប់ផ្សេងៗ និងទឹកលុបពណ៌ស

៥-មិនត្រូវចូលក្នុងបន្ទប់ប្រឡងមុនពេលអនុរក្សហៅឈ្មោះ

៧

៦-មិនត្រូវប្រើពាក្យសំដី អាកប្បកិរិយាមិនសមរម្យក្នុងមណ្ឌលប្រឡង ឬបង្កជម្លោះនៅក្នុងមណ្ឌលប្រឡង ឬក្នុងបន្ទប់ប្រឡង ដោយគម្រាមកំហែងលើបេក្ខជនដទៃ

៧-មិនត្រូវបដិសេធ ប្រឆាំងតបត ឬបង្កបាតុភាពដោយពាក្យសំដី ដោយកាយវិការ ចំពោះការត្រួតពិនិត្យរបស់អ្នកមានសមត្ថកិច្ច ឬមេប្រយោគក្នុងការពិនិត្យស្រាវជ្រាវរើកសំណៅ ឯកសារ និងសម្ភារៈផ្សេងៗ ដែលត្រូវហាមឃាត់មិនឱ្យយកចូលក្នុងមណ្ឌលប្រឡង

៨-មិនត្រូវធ្វើចម្លើយវិញ្ញាសា នៅលើសន្លឹកកិច្ចការណា ដែលគ្មានហត្ថលេខារបស់អនុរក្ស

៩-មិនត្រូវចម្លងប្រធានវិញ្ញាសាចូលក្នុងក្រដាសដទៃ និងមិនត្រូវបោះប្រធានវិញ្ញាសាចេញក្រៅបន្ទប់ប្រឡងឡើយ

១០-មិនត្រូវងើបឈរ ងាកឆ្វេង-ស្តាំ អើតឈ្ងោកទៅមុខ បែរទៅក្រោយ ឬដើរចេញពីកន្លែងអង្គុយដោយគ្មានការអនុញ្ញាតពីអនុរក្ស។ មិនត្រូវសរសេរកិច្ចការហើយអានខ្លាំងៗ ឮដល់អ្នកជិតខាង ឬឆក់អូសទាញយកសន្លឹកកិច្ចការរបស់អ្នកដទៃដាក់ពីមុខ ឬដាក់ពីក្រោមសន្លឹកកិច្ចការរបស់ខ្លួនឡើយ

១១-មិនត្រូវប្តូរគ្នានូវសន្លឹកកិច្ចការ ឬក្រដាសព្រាង ឬផ្ទៀងផ្ទាត់ចម្លើយ ឬចម្លងគ្នា និងមិនត្រូវដាក់សន្លឹកកិច្ចការឆ្ងាយពីមុខរបស់ខ្លួន បង្កឱ្យអ្នកដទៃមើល ឬអូសឆក់យកបាន

១២-មិនត្រូវធ្វើសញ្ញាសម្គាល់លើសន្លឹកកិច្ចការ ដើម្បីធ្វើឱ្យគេស្គាល់អាគតដ្ឋានរបស់ខ្លួនដូចជា សរសេរអក្សរប្លែកពីតួអក្សរទាំងអស់ក្នុងកិច្ចការ ធ្វើសញ្ញាផ្សេងៗ ឬគូសបន្ទាត់ខុសប្រក្រតី ឬលុបនឹងទឹកស ឬសរសេររំលងបន្ទាត់ជាដើម

១៣-មិនត្រូវលាក់ ឬហែកសន្លឹកកិច្ចការរបស់ខ្លួន និងមិនត្រូវហែក ឬលាក់សន្លឹកកិច្ចការអ្នកដទៃ

១៤-មិនត្រូវបំផ្លាញ ឬធ្វើឱ្យខូចខាតសម្ភារៈនៅក្នុងបន្ទប់ប្រឡង ដូចជាដោះទ្វារ បង្អួច ធ្វើឱ្យរបើកជញ្ជាំងក្តារ ធ្វើឱ្យបាក់បែកតុ កៅអី ឬក្តារខៀនជាដើម

១៥-មិនត្រូវឱ្យអ្នកដទៃប្រឡងជំនួសឬសរសេរបំពេញបន្ថែមលើសន្លឹកកិច្ចការរបស់ខ្លួនជាដាច់ខាត

១៦-មិនត្រូវប្រើពាក្យសំដី និងអាកប្បកិរិយា ដែលនាំឱ្យខូចសណ្តាប់ធ្នាប់របៀបរៀបរយនៃការប្រឡង ឬប៉ះពាល់ដល់កិត្តិយសរបស់មេប្រយោគ។